# របាយការណ៍ប្រចាំ ឆ្នាំ២០១៧

## ស្ដីអំពី

## ការអប់រំផ្សព្វផ្សាយមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

## ការអភិវឌ្ឍក្រោយការបោសសំអាតមីន ការសិក្សាស្រាវជ្រាវ

## និងអភិវឌ្ឍន៍បច្ចេកទេស



នាយកដ្ឋានអប់រំផ្សព្វផ្សាយ ជួយជនរងគ្រោះដោយសារមីន

និងអភិវឌ្ឍន៍ក្រោយការបោសសំអាតមីន

ភ្នំពេញ, ខែមករា ឆ្នាំ២០១៨

## A) ផ្នែកអប់រំផ្សព្វផ្សាយ ជួយជនរងគ្រោះដោយសារមីន

### ក- ស្ថានភាពទូទៅ

ក្នុងឆ្នាំ២០១៧កន្លងមកនេះ ស្ថានភាពរងគ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ បានថយចុះប្រមាណ៣០% បើប្រៀបធៀបទៅនឹងអត្រាគ្រោះថ្នាក់នៃឆ្នាំ២០១៦ កន្លងមក ហើយសកម្មភាពដែលបង្កឱ្យមានគ្រោះថ្នាក់កើតឡើងច្រើនតែដោយសារសកម្មភាពកែឆ្នៃគ្រាប់, ការលេងគ្រាប់ និងការរុករានដី។ល។ ចំណែកឯគ្រោះថ្នាក់ដោយសារមីនតោនក្នុងឆ្នាំ២០១៧នេះ បានថយចុះនៅត្រឹមតែ៧ករណីប៉ុណ្ណោះ បណ្តាលឱ្យមានមនុស្សស្លាប់ និងរបួសតែ៣នាក់ប៉ុណ្ណោះ។

តាមទិន្នន័យ CMVIS ស្ថានភាពគ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះបានបញ្ជាក់ថា រយៈពេល៥ឆ្នាំចុងក្រោយនេះ ចាប់ពីឆ្នាំ២០១៣-២០១៧ មានស្រុកចំនួន០៨ ដែលមានអត្រាគ្រោះថ្នាក់ខ្ពស់ជាងគេគឺ ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ស្រុកសំឡូត ក្នុងខេត្តបាត់ដំបង ស្រុកថ្មពួកក្នុងខេត្តបន្ទាយមានជ័យ ស្រុកត្រពាំងប្រាសាទ និងស្រុកសំរោងក្នុងខេត្តឧត្តរមានជ័យ ស្រុកវាលវែង ក្នុងខេត្តពោធិ៍សាត់ និងស្រុកសាលាក្រៅ ក្រុងប៉ៃលិនក្នុងខេត្តប៉ៃលិន។

ការងារអប់រំការយល់ដឹងពីគ្រោះថ្នាក់មីន/គ្រាប់មិនទាន់ផ្ទុះ នៅតែមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ទទួលរងការប៉ះពាល់ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ ដូចជានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងព្រំដែនកម្ពុជា-វៀតណាម ក្នុងខេត្តមួយចំនួនដូចជា ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរី។ ក្រៅពីនេះនៅមានខេត្តមួយចំនួនទៀត ជុំវិញរាជធានីភ្នំពេញមានដូចជា ខេត្តកណ្តាល កំពង់ឆ្នាំង ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ក្រុងព្រះសីហនុ និងខេត្តកោះកុង ក៏ត្រូវការអប់រំផ្សព្វផ្សាយយល់ដឹងពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដ៏ចាំបាច់ផងដែរ។

ទិន្នន័យជនរងគ្រោះថ្នាក់មីន/UXOs ពីឆ្នាំ១៩៩៩ - ២០១៧



## ខ- ស្ថានភាពបុគ្គលិក

កម្មវិធីអប់រំការយល់ដឹងពីមីន និងគ្រាប់មិនទាន់ផ្ទុះ មានបុគ្គលិកសរុបចំនួន២៣នាក់ ហើយនឹងកំពុងតែពង្រឹង/ពង្រីកសមត្ថភាព ដល់គណៈកម្មាធិការមីនស្ម័គ្រចិត្ត/គ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្ត និងមេភូមិ នាយប៉ុស្តិ៍នគរបាលទូទាំងប្រទេសចំនួន១,១០៣នាក់ ដែលពួកគាត់កំពុងតែបំពេញប្រតិបត្តិការនៅក្នុងតំបន់ទទួលរងនូវការគំរាមកំហែងពីមីន/គ្រាប់មិនទាន់ផ្ទុះនានា មានដូចខាងក្រោម៖

### *ក/បុគ្គលិក:*

| | |
|---|---|
| ១-ប្រធាននាយកដ្ឋាន | ០១ នាក់ |
| ២-អនុប្រធាននាយកដ្ឋាន | ០១ នាក់ |
| ៣-ប្រធានការិយាល័យអប់រំផ្សព្វផ្សាយមីន និងជួយជនពិការដោយសារមីន | ០១ នាក់ |
| ៤-នាយសម្របសម្រួលការងារមីនប្រចាំខេត្ត | ០២ នាក់ |
| ៥-នាយតំណាងមីនប្រចាំស្រុកCBMRR-DFP | ១៧ នាក់ |

សរុបរួម:២២នាក់

ចំពោះបុគ្គលិកអប់រំមីនមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសនៅក្នុងខែធ្នូ២០១៤ ហើយនៅក្នុងខែធ្នូ ឆ្នាំ២០១៧នេះ មានចំនួនត្រឹម ២២នាក់ប៉ុណ្ណោះ។ ចំពោះស្ថានភាពបុគ្គលិកពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៧ មានលម្អិតក្នុងតារាងលេខ១ ខាងក្រោម៖

| ក្រុមប្រតិបត្តិការ | ចំនួនបុគ្គលិក | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | 6-2011 | 12-2011 | 12-2012 | 6-2013 | 12-2013 | 6-2014 | 12-2014 | 6-2015 | 12-2015 | 12-2016 | 12-2017 |
| Director MRE& VA/PCD | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| Dep.Director MRE/VA/PCD | | | | | | 1 | 1 | 1 | 1 | 1 | 1 |
| Chief Of MRE | | | | | | | | | | 1 | 1 |
| MRE Officer | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 0 | 0 |
| CBMRR-TMO | 1 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| CBMRR-PC | 2 | 3 | 4 | 4 | 4 | 4 | 4 | 4 | 4 | 3 | 2 |
| MRER Team | 13 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| CBMRR-DFP | 17 | 20 | 23 | 24 | 24 | 24 | 24 | 17 | 17 | 17 | 17 |
| CBURR-DFP | 19 | 18 | 18 | 18 | 18 | 18 | 0 | 0 | 0 | 0 | 0 |
| **សរុប** | **51** | **48** | **48** | **49** | **48** | **49** | **31** | **24** | **24** | **23** | **22** |

តារាងលេខ១៖ ស្ថានភាពបុគ្គលិកអប់រំមីនពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៧

### *ខ/អ្នកស្ម័គ្រចិត្ត:*

១-កម្មវិធី CBMRR

១- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ទាំង០៣កំរិត ៦៤១នាក់

២- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ទើបបង្កើតថ្មី ១៥០នាក់

<u>សរុបៈ៧៩១នាក់</u> កំពុងដំណើរការ

៣- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ចាកចេញពីកម្មវិធី (Phase Out): <u>២៥៦</u>នាក់

២-កម្មវិធី CBURR

១-គណៈកម្មាធិការគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្ត CBURR ៣១២នាក់

២-មេភូមិ និងនាយប៉ុស្តិ៍នគរបាល ១៥០នាក់

៣-មេភូមិ និងមន្ត្រីនគរបាល(ថ្មី២០១៧)២ខេត្តៈ

ស្វាយរៀង និងព្រៃវែង ៦០នាក់

៤-មេភូមិ (ថ្មី២០១៧)នៅស្រុកជាំក្សាន្ត ១៦០នាក់

៥-មន្ត្រីនគរបាល(ថ្មី២០១៧)៤ខេត្តៈ កំពង់ធំ,សៀមរាប,

ឧត្តរមានជ័យ និងព្រះវិហារ ១០០នាក់

<u>សរុបៈ៧៨២នាក់</u> កំពុងដំណើរការ

៣-គណៈកម្មាធិការគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្ត CBURR ចាកចេញពីកម្មវិធី ១២៨នាក់

**សរុបរួមទាំង២កម្មវិធី អ្នកស្ម័គ្រចិត្តដែលបង្កើតបានចំនួនៈ <u>១,៩៥៧នាក់</u>**

រូបភាពកម្មវិធីCBM





រូបភាពកម្មវិធីCBU



## គ- ការពង្រាយកម្លាំង

## ១-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍

Community Based Mine Risk Reduction(CBMRR)

មានបុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP)ម្នាក់ នៅតាមស្រុកគោលដៅទាំង២៤ បច្ចុប្បន្ននេះដាច់គំពេង៧នាក់ នៅតែ១៧នាក់កំពុងដំណើរការរាល់ថ្ងៃ។ មានសមាសភាពជ្រើសចេញមកពីមន្ត្រីជំនាញជុំវិញសាលាស្រុកជួយធ្វើការសម្របសម្រួលលើសេវាកម្មទាំងបីមាន សេវាកម្មមីន, សេវាកម្មអភិវឌ្ឍន៍ និងសេវាកម្មជនពិការក្នុងការពង្រឹង/ពង្រីកសមត្ថភាពដល់បណ្តាញមីនស្ម័គ្រចិត្តទាំង<u>៧៩១</u>នាក់ នៅកម្រិតភូមិ-

ឃុំ ស្រុក សមាសភាពជា(មេភូមិ,ក្រុមប្រឹក្សាឃុំ/សង្កាត់,មន្ត្រីជំនាញជុំវិញសាលាស្រុក) ដើម្បីឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចេះប្រមូលយកព័ត៌មានតាមបែបចូលរួម (PLA) វិភាគបញ្ហា/កំណត់តម្រូវការភូមិ តាមរយៈចំណាត់អាទិភាពតម្រូវការ ហើយយកតម្រូវការនេះទៅរៀបចំជាផែនការសកម្មរបស់ភូមិ ដើម្បីងាយស្រួល និងតាមដានបញ្ចូលផែនការវិនិយោគឃុំ/សង្កាត់ ពិសេសផែនការបោសសំអាតមីន ព្រមទាំងជួយអប់រំផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពមីន/គ្រាប់មិនទាន់ផ្ទុះ បន្តដល់សហគមន៍មូលដ្ឋានរបស់ពួកគេជាប្រចាំលើភូមិគោលដៅចំនួន២៨៤ភូមិ ឃុំគោលដៅចំនួន៩៦ឃុំ ក្នុង២៦ស្រុកគោលដៅ ក្នុងខេត្តទាំង៦មាន៖

- ខេត្តពោធិ៍សាត់មាន២ស្រុកគឺៈ ភ្នំក្រវាញ និងស្រុកវាលវែង។
- ខេត្តបាត់ដំបងមាន១០ស្រុកគឺៈ ស្រុកមោងឬស្សី ស្រុករុក្ខគិរី ស្រុកគាស់ក្រឡ ស្រុកបាណន់ ស្រុករតនមណ្ឌល ស្រុកសំឡូត ស្រុកបវេល ស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន។
- ខេត្តប៉ៃលិនមាន២ស្រុកគឺៈ ក្រុងប៉ៃលិន និងខណ្ឌសាលាក្រៅ។
- ខេត្តបន្ទាយមានជ័យមាន៥ស្រុកគឺៈ ស្រុកម៉ាឡៃ ស្រុកអូរជ្រៅ ក្រុងប៉ោយប៉ែត ស្រុកស្វាយចេក និងស្រុកថ្មពួក។
- ខេត្តឧត្តរមានជ័យ៣ស្រុកគឺៈ ស្រុកបន្ទាយអំពិល ស្រុកសំរោង ស្រុកត្រពាំងប្រាសាទ (បុគ្គលិក DFPទាំង៣នេះ បានចប់គំរោងតាំងក្នុងខែមេសា ឆ្នាំ២០១៥)។
- ខេត្តព្រះវិហារមាន៤ស្រុកគឺៈស្រុកគូលែន ជាំក្សាន្ត ត្បែងមានជ័យ និងស្រុកឆែប។ (បុគ្គលិកDFPទាំង៤នេះ បានចប់គំរោងតាំងពីខែធ្នូ ឆ្នាំ២០១៤)។

## ២-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍

Community Based UXO Risk Reduction(CBURR)

កម្មវិធីនេះយើងពង្រីកបាន៦៦ស្រុក ឋិតក្នុង១១ខេត្តគោលដៅ ដែលយើងបានធ្វើការសាកល្បងរកគន្លឹះគ្រប់គ្រង និងបង្កើនការងារអប់រំផ្សព្វផ្សាយយល់ដឹងពីមីន ឱ្យបានទូលំទូលាយជាសាធារណៈ ក្នុងសហគមន៍មូលដ្ឋាន ដោយចែកចេញជា០៣ដំណាក់កាលដូចខាងក្រោម៖

### ២.១-ដំណាក់កាលទី១

កម្មវិធីបង្កើតឱ្យមានបុគ្គលិក នាយតំណាងគ្រាប់មិនទាន់ផ្ទុះប្រចាំស្រុក(DFP)ម្នាក់នៅតាមស្រុកគោលដៅទាំង១៨ ដែលមានសមាសភាពជ្រើសចេញមកពីមន្ត្រីនគរបាលស្រុក ជួយធ្វើការសំរបសំរួលលើសេវាកម្មមីន ក្នុងការបង្ហាញពីទីតាំងមីន/គ្រាប់មិនទាន់ផ្ទុះសេសសល់ពីសង្គ្រាម និងធ្វើការអប់រំផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពមីន/គ្រាប់មិនទាន់ផ្ទុះដល់ប្រជាពលរដ្ឋទូទៅក្នុងស្រុករបស់ខ្លួនតាមរយៈការប្រមូលព័ត៌មានពីបញ្ហាមីន/គ្រាប់មិនទាន់ផ្ទុះ ជូនមកប្រតិបត្តិករបោសសំអាតមីន/គ្រាប់មិនទាន់ផ្ទុះ ដើម្បីធ្វើការកម្ទេចចោលចំនួន៤ខេត្ត រួមមានៈ

- ខេត្តកំពង់ឆ្នាំងមានចំនួន៦ស្រុកគឺៈ ស្រុករលាប្អៀរ ស្រុកសាមគ្គីមានជ័យ ស្រុកទឹកផុស ក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច និងស្រុកបរិបូណ៌។

- ខេត្តកំពង់ធំមានចំនួន៣ស្រុកគឺៈ ស្រុកស្ទោង ស្រុកស្ទឹងសែន និងស្រុកបារាយណ៍។
- ខេត្តពោធិ៍សាត់មានចំនួន៣ស្រុកគឺៈ ក្រុងពោធិ៍សាត់ ស្រុកបាកាន និងស្រុកក្រគរ។
- ខេត្តសៀមរាបមានចំនួន៦ស្រុកគឺៈ ស្រុកជីក្រែង ស្រុកស្វាយលើ ស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី ស្រុកអង្គរធំ និងស្រុកប្រាសាទបាគង ប៉ុន្តែគំរោងខាងលើនេះត្រូវបានបញ្ចប់ក្នុងខែតុលាឆ្នាំ២០១៤ កន្លងមកនេះ។

### ២.២-ដំណាក់កាលទី២

បង្កើតឱ្យមានជាបណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តប្រចាំភូមិម្នាក់ និងឃុំម្នាក់ នៅតាមស្រុកគោលដៅទាំង២៧ ដោយពុំចាំបាច់ចំណាយថវិកាសម្រាប់បង្កើតបុគ្គលិកទេ ក្នុងគោលបំណងពង្រីកបណ្តាញស្ម័គ្រចិត្តឱ្យបានច្រើនជាអតិបរិមា ធ្វើឱ្យការផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពបន្តទៅក្នុងសហគមន៍មូលដ្ឋាន បានទូលំទូលាយជាសាធារណៈ និងការផ្តល់ព័ត៌មានគ្រាប់មិនទាន់ផ្ទុះត្រឡប់មកវិញតាមរយៈការយល់ដឹងរបស់ពួកគេជាបន្តបន្ទាប់ (របៀបភ្នែកម្ចាស់) ជូនមកប្រតិបត្តិករបោសសំអាតមីន/ គ្រាប់មិនទាន់ផ្ទុះ ដើម្បីធ្វើការកម្ទេចចោល។ សមាសភាពជ្រើសថ្នាក់មេភូមិ ជាបណ្តាញស្ម័គ្រចិត្តភូមិ នាយប៉ុស្តិ៍នគរបាលឃុំ/សង្កាត់ ជាបណ្តាញស្ម័គ្រចិត្តឃុំ ដែលមានចំនួន៤៦២នាក់ ឋិតក្នុងភូមិគោលដៅចំនួន៣០៩ភូមិ, ឃុំចំនួន១៥៨ឃុំ លើ២៧ស្រុក នៃ៥ខេត្តរួមមានៈ

- ខេត្តកំពង់ចាមមានចំនួន៦ស្រុកគឺៈ ស្រុកបាធាយ ស្រុកជើងព្រៃ ស្រុកព្រៃឈរ ស្រុកចំការលើ ស្រុកកំពង់សៀម ស្រុកស្ទឹងត្រង់។
- ខេត្តត្បូងឃ្មុំមានចំនួន៦ស្រុក-ក្រុង គឺៈ ក្រុងសួង ស្រុកត្បូងឃ្មុំ និងស្រុកពញាក្រែក ស្រុកតំបែរ ស្រុកមេមត់ និងស្រុកអូររាំងឪ។
- ខេត្តក្រចេះមានចំនួ៥ស្រុកគឺៈ ស្រុកស្នួល ស្រុកចិត្របុរី ស្រុកសម្បូរ ស្រុកព្រែកប្រសព្វ និងស្រុកឆ្លូង។
- ខេត្តស្វាយរៀងមានចំនួន៧ស្រុកគឺៈ ស្រុកស្វាយរៀង ស្រុកចន្ទ្រា ស្រុករមាសហែក ស្រុកស្វាយទាប ស្រុករំដួល ស្រុកស្វាយជ្រុំ និងស្រុកកំពង់រោទ៍។
- ខេត្តព្រៃវែងមានចំនួន៤ស្រុកគឺៈ ស្រុកកំចាយមារ ស្រុកព្រះស្តេច ស្រុកបាភ្នំ និងស្រុកកំពង់ត្របែក។

*បច្ចុប្បន្ននេះ បណ្តាញស្ម័គ្រចិត្តគ្រាប់មិនទាន់ផ្ទុះ(ភូមិ/នាយប៉ុស្តិ៍នគរបាលឃុំ)ទាំង៤៦២នាក់ខាងលើ ពុំទាន់បានបង្កើតនាយសម្របសម្រួលការងារគ្រាប់មិនទាន់ផ្ទុះសម្រាប់គ្រប់គ្រង ប្រចាំកងឯកភាពកំចាត់មីនទី៥ នៅឡើយទេ ដូច្នេះការប្រមូលរបាយការណ៍អប់រំពីពួកគាត់ត្រូវគាំងមិនដំណើរការ។*

### ២.៣-ដំណាក់កាលទី៣

ថ្មីៗនេះនៅក្នុងឆ្នាំ២០១៧ យើងបានបង្កើតឱ្យមានជាបណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្ត ប្រចាំភូមិម្នាក់ជាមេភូមិ និងមន្ត្រីនគរបាល នៅតាមស្រុកគោលដៅទាំង៣២ ឃុំ៧៩ និងភូមិ៨២ ដែលមានមនុស្សចំនួន៣២០នាក់ ក្នុងខេត្តចំនួន៦គឺៈ មានខេត្តស្វាយរៀង, ព្រៃវែង, កំពង់ធំ, សៀមរាប, ឧត្តរមានជ័យ និងព្រះវិហារ ក្នុងនោះយើងបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង កិច្ចការប៉ុស្តិ៍របស់ស្នងការខេត្តទាំង៦ ដោយយក

សមាសភាពមេភូមិ នាយប៉ុស្តិ៍រដ្ឋបាល អធិការរងទទួលកិច្ចការប៉ុស្តិ៍ និងប្រធានការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍នៃស្នងការខេត្តជាអ្នកគ្រប់គ្រងព័ត៌មាន និងផ្តល់របាយការណ៍ខែ ដែលពួកគាត់អប់រំបានបញ្ជូនមកទីបញ្ជាការភ្នំពេញតាមរយៈជំនួយការទិន្នន័យតាមកងឯកភាពកំចាត់មីនទី៥ និងទី៤ ដោយយើងផ្តល់តែថវិកាលើកទឹកចិត្តជាCell card ប្រចាំខែដល់ពួកគាត់តែប៉ុណ្ណោះ ដើម្បីភ្ជាប់ជាមួយភារកិច្ចរបស់ពួកគាត់ក្នុងចំណុចទី៧ ស្តីពីការងារអប់រំមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងគោលនយោបាយ (ភូមិ-ឃុំមានសុវត្ថិភាព)។ ចំនួនអ្នកស្ម័គ្រចិត្តមានដូចខាងក្រោម៖

- ខេត្តស្វាយរៀងមានចំនួន២ស្រុកគឺៈ ស្រុករមាសហែក និងស្រុកស្វាយជ្រុំចំនួន៣២នាក់ ក្នុងនោះមាន(មេភូមិ១០នាក់ មន្ត្រីម៉ាពូ១នាក់ និងមន្ត្រីនគរបាល២១នាក់)
- ខេត្តព្រៃវែងមានចំនួន៤ស្រុកគឺៈ ស្រុកពារាំង ស្រុកពាមរោរ៍ ស្រុកស្វាយអន្ទរ និងស្រុកពោធិ៍រៀងចំនួន២៨នាក់ (មេភូមិ១៣នាក់ មន្ត្រីម៉ាពូ១នាក់ និងមន្ត្រីនគរបាល១៤នាក់)
- ខេត្តកំពង់ធំមានចំនួន៦ស្រុកគឺៈ ស្រុកកំពង់ស្វាយ ប្រាសាទបល្ល័ង្គ ប្រាសាទសំបូរ សណ្តាន់ សន្ទុក និងស្រុកបារាយណ៍ ចំនួន២៣នាក់ (មន្ត្រីនគរបាល២២នាក់ និងមន្ត្រីម៉ាពូ១នាក់)
- ខេត្តសៀមរាបមានចំនួន៧ស្រុកគឺៈ ស្រុកអង្គរធំ បន្ទាយស្រី ជីក្រែង វ៉ារិន ប្រាសាទបាគង សូទ្រនិគម និងស្រុកស្វាយលើ ចំនួន២៧នាក់ (មន្ត្រីនគរបាល២៦នាក់ និងមន្ត្រីម៉ាពូ១នាក់)
- ខេត្តឧត្តរមានជ័យមានចំនួន៥ស្រុកគឺៈ ស្រុកបន្ទាយអំពិល ចុងកាល់ សំរោង អន្លង់វែង និងត្រពាំងប្រាសាទ ចំនួន២៤នាក់ (មន្ត្រីនគរបាល២៣នាក់ និង មន្ត្រីម៉ាពូ១នាក់)
- ខេត្តព្រះវិហារមានចំនួន៨ស្រុកគឺៈ ក្រុងព្រះវិហារ ត្បែងមានជ័យ សង្គមថ្មី រវៀង គូលែន ជ័យសែន ស្រុកឆែប និងស្រុកជាំក្សាន្ត ចំនួន១៨៧នាក់ (មេភូមិ១៦០នាក់ មន្ត្រីនគរបាល២៦នាក់ និង មន្ត្រីម៉ាពូ១នាក់)។

### ៣-ក្រុមអប់រំផ្សេងៗ

ក្រៅពីក្រុមអប់រំខាងលើ ការអប់រំយល់ដឹងពីមីន/គ្រាប់មិនទាន់ផ្ទុះក៏បានអនុវត្តនៅតាមក្រុមប្រតិបត្តិការផ្សេងៗដូចជាក្រុម EOD, BAC, BAC-L, BAC-MTT, BAC-S, BAV, BC, DM, ERWI, LLD, MDR, NTS, OPS DU, SLD, TSC, Asst OPS និងPlatoon ដែលកំពុងបំពេញប្រតិបត្តិការ នៅតាមកងឯកភាពកំចាត់មីននានា និងក្រុមស្ថិតនៅក្រោមចំណុះទីបញ្ជាការភ្នំពេញ។

## គ-លទ្ធផលសម្រេចបាន

### ១-ការអប់រំៈចាប់ពីខែមករា រហូតដល់ ខែធ្នូ ឆ្នាំ២០១៧ គ្រប់ក្រុមអប់រំការយល់ដឹងពីមីន និងគ្រាប់មិនទាន់ផ្ទុះ សម្រេចបានលទ្ធផលដូចខាងក្រោមៈ

១.១-ការអប់រំរបស់គណៈកម្មាធិការមីនស្ម័គ្រចិត្តកម្មវិធី CBMRR&CBURR និងក្រុមចល័តនានា

ក្នុងឆ្នាំ២០១៧នេះ មាន១២៨ក្រុម បានធ្វើការអប់រំយល់ដឹងពីមីន ដែលទទួលបានលទ្ធផល ដូចមានលំអិតជូននៅក្នុងតារាងលេខ២ ខាងក្រោមនេះ៖

| ក្រុម | ចំនួនក្រុម | ចំនួនមនុស្សដែលទទួលបានការអប់រំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | លើក | បុរស | ស្ត្រី | កុមារក្នុងប្រព័ន្ធ | កុមារក្រៅប្រព័ន្ធ | សរុប | ខ្នងផ្ទះ |
| Asst OPS | 1 | 21 | 67 | 59 | | 63 | 189 | |
| BAC | 5 | 33 | 142 | 137 | 39 | 101 | 419 | 19 |
| BAC-L | 5 | 75 | 402 | 273 | 23 | 34 | 732 | 2 |
| BAC-MTT | 8 | 956 | 3,616 | 2,754 | 2,556 | 4,440 | 13,366 | 299 |
| BAC-S | 14 | 1,290 | 6,929 | 5,100 | 2,783 | 2,680 | 17,492 | 18 |
| BAV | 1 | 3 | 35 | 23 | | 9 | 67 | |
| BC | 5 | 77 | 336 | 321 | 4 | 8 | 669 | 19 |
| CBMRR | 18 | 5,113 | 34,359 | 31,908 | 24,472 | 8,260 | 98,999 | 5,076 |
| CBURR | 10 | 39 | 1,652 | 2,221 | 689 | 342 | 4,904 | 42 |
| DM | 8 | 104 | 504 | 293 | 98 | 91 | 986 | 12 |
| EDD | 4 | 341 | 1,002 | 889 | 107 | 540 | 2,538 | 9 |
| ERWI | 11 | 539 | 1,810 | 791 | 4,204 | 1,691 | 8,496 | 412 |
| LLD | 1 | 32 | 111 | 75 | | 128 | 314 | |
| MDR | 1 | 8 | 120 | 92 | | | 212 | |
| NTS | 5 | 182 | 2,264 | 1,067 | 523 | 533 | 4,387 | 98 |
| OPS DU | 1 | 82 | 236 | 266 | 55 | 381 | 938 | |
| Platoon | 9 | 140 | 542 | 351 | 66 | 181 | 1,140 | 15 |
| SLD | 3 | 22 | 115 | 109 | 184 | 81 | 489 | 14 |
| TSC | 18 | 273 | 1,257 | 984 | 173 | 381 | 2,795 | 36 |
| **Total** | **128** | **9,330** | **55,499** | **47,713** | **35,976** | **19,944** | **159,132** | **6,071** |

តារាងលេខ២៖ លទ្ធផលអប់រំយល់ដឹងពីមីនក្នុងឆ្នាំ២០១៧

### ១.២-ការអប់រំរបស់នាយតំណាងមីនប្រចាំស្រុកទាំង១៧ CBMRR – DFP ដល់អ្នកប្រើប្រាស់គ្រឿងចក្រគ្រប់ប្រភេទក្នុងតំបន់សង្ស័យមានមីនគោន

ឆ្នាំ២០១៧នេះ នាយតំណាងមីនប្រចាំស្រុក(DFP)កម្មវិធី CBMRR បានចុះធ្វើការអប់រំដោយផ្ទាល់ដល់អ្នកប្រើប្រាស់គ្រឿងចក្រនានា នៅក្នុងតំបន់ដែលមីនគោន អ្នករុករានដីកសិកម្មនៅក្នុងតំបន់ដែលមិនទាន់មានការបោសសំអាតមីន ធ្វើបច្ចុប្បន្នភាពមីនគោនលើផែនទីភូមិ និងអប់រំអ្នកមានចរឹតចចេសរឹងរូស ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

| តំបន់គោលដៅ | ម្ចាស់គ្រឿងចក្រ | អ្នកពង្រីកដីកសិកម្មក្នុងតំបន់មីន | អ្នកក្រីក្រប្រឈមនឹងគ្រោះថ្នាក់មីន | ជនចចេសរឹងរូស | ធ្វើបច្ចុប្បន្នភាពផែនទីនូវព័ត៌មានមីនគោន | លទ្ធផលសំរេចបានជាភាគរយ |
|---|---|---|---|---|---|---|
| **DU1** | 2,050 | 1,940 | 1,280 | 65 | 5 | 100% |
| **DU2-BTB** | 2,810 | 1,990 | 2,260 | 75 | 8 | 101.90% |
| **DU2-PLN** | 1,802 | 1160 | 990 | 55 | 7 | 103.10% |
| **Total** | **6,662** | **5,090** | **4,530** | **195** | **20** | **100.50%** |

តារាងលេខ៣៖ លទ្ធផលអប់រំយល់ដឹងពីមីនគោន ឆ្នាំ២០១៧









លទ្ធផលសរុបទទួលបានលើស **<u>100.50%</u>** នៃសន្ទស្សន៍ផែនការប្រចាំឆ្នាំ២០១៧ ដោយបុគ្គលិក DFP យើងមានឆន្ទៈមុះមុតក្នុងការងារសម្រេចបាននូវលទ្ធផលគួរជាទីគាប់ចិត្ត។

## ២-ការរាយការណ៍ពីមីន/UXOs និងការប្រើប្រាស់សម្ភារៈ

ឆ្នាំ២០១៧ ចាប់ពីខែមករា រហូតដល់ខែធ្នូ(រយៈពេល១២ខែ)ក្រុមអប់រំការយល់ដឹងពីគ្រោះថ្នាក់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងអស់ ទទួលបានសំណើកម្ទេចមីន និងគ្រាប់មិនទាន់ផ្ទុះ សរុបចំនួន<u>៧,០៤៥</u> សំណើ និងបានសម្របសម្រួល និងឆ្លើយតបបានចំនួន<u>៦,៧៩១</u>សំណើ។ ចំពោះលទ្ធផលលម្អិតតាមក្រុម និងការប្រើ ប្រាស់សម្ភារៈអប់រំមានក្នុង**តារាងលេខ៤** និង**តារាងលេខ៥**។

| Team | Mine/UXO Reported | | | | | | Mine/UXO Responded | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | Number of Repuest | AP | AT | UXO | Caliber (kg) | **Total** | Number of Repuest | AP | AT | UXO | Caliber (kg) | **Total** |
| Asst OPS | 4 | | | 4 | | 4 | 4 | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| BAC | 93 | 134 | 2 | 677 | 231 | 813 | 93 | 134 | 2 | 677 | 231 | 813 |
| BAC-L | 6 | | | 9 | | 9 | 3 | | | 7 | | 7 |
| BAC-MTT | 403 | | | 634 | | 634 | 436 | | | 761 | | 761 |
| BAC-S | 45 | 14 | 1 | 293 | | 308 | 44 | 14 | 1 | 276 | | 291 |
| BAV | | | | | | | | | | | | |
| BC | 6 | 1 | | 6 | | 7 | 6 | 1 | | 6 | | 7 |
| CBMRR | 716 | 680 | 34 | 2,236 | | 2,950 | 577 | 605 | 32 | 1,977 | 10 | 2,614 |
| CBURR | 2 | | | 2 | | 2 | 2 | | | 2 | | 2 |
| DM | 5 | 5 | | 8 | | 13 | 6 | 5 | | 13 | | 18 |
| EDD | 3 | | | 3 | | 3 | 3 | | | 3 | | 3 |
| ERWI | 467 | 154 | 1 | 2,086 | 5 | 2,241 | 459 | 154 | 2 | 2,078 | 7 | 2,234 |
| LLD | | | | | | | | | | | | |
| MDR | | | | | | | | | | | | |
| NTS | 18 | 38 | 1 | 12 | | 51 | 13 | 24 | 1 | 9 | | 34 |
| OPS DU | 21 | | | | | | | | | | | |
| Platoon | | | | | | | | | | | | |
| SLD | 4 | 4 | | 4 | | 8 | 3 | 4 | | 1 | | 5 |
| TSC | 1 | 1 | | 1 | | 2 | 1 | 1 | | 1 | | 2 |
| Grand Total: | 1,794 | 1,031 | 39 | 5,975 | 236 | 7,045 | 1,650 | 942 | 38 | 5,811 | 248 | 6,791 |

តារាងលេខ៨៖ ការទទួលរបាយការណ៍គ្រាប់ និងការឆ្លើយតប

| Team | MRE Material Used | | | | | | | |
|---|---|---|---|---|---|---|---|---|
| | Big T-Shirt | Smal T-Shirt | Note Book | Poster | Flyer | Leaflet | VCD | Others |
| Asst OPS | | | | | | | | |
| BAC | | | | | | | | 214 |
| BAC-L | | | | 11 | 2 | 2 | | |
| BAC-MTT | | | | | | | | |
| BAC-S | | | | 175 | 371 | | | |
| BAV | | | | | | | | |
| BC | | | | | 1 | 1 | | |
| CBMRR | 3,000 | 164 | 4,500 | 3,000 | 922 | 3,000 | | |
| CBURR | 1,000 | | 2,500 | 1,300 | | 2,000 | | |
| DM | | | 13 | | 1 | | | |
| EDD | | | 49 | 2 | 13 | 1 | | 6 |
| ERWI | | | 451 | 25 | | | | |
| LLD | | | | | | | | |
| MDR | | | | | | | | |
| NTS | | | 617 | 230 | | | | |
| OPS DU | | | | | | | | |
| Platoon | | | 100 | 15 | | | | |
| SLD | | | | | | | | |
| TSC | | | | | 3 | | | |
| **Grand Total:** | **4,000** | **164** | **8,230** | **4,758** | **1,313** | **5,004** | | **220** |

តារាងលេខ៩៖ ការប្រើប្រាស់សម្ភារៈអប់រំ

## ៣-សកម្មភាពការិយាល័យ:

៣.១- ថ្ងៃទី០១-០៥ខែមករា ឆ្នាំ២០១៧ ចូលរួមសម្របសម្រួល និងជ្រើសរើសជនពិការ១២០នាក់ ពីតាមខេត្តមកធ្វើ និងទទួលជើងសិប្បនិម្មិតនៅទីបញ្ជាការស៊ីម៉ាក់ភ្នំពេញ។





៣.២-ថ្ងៃទី១៧ខែមករាឆ្នាំ២០១៧ ចុះប្រមូលព័ត៌មានគ្រាប់បែកគីមីនៅភូមិគគីរ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។





៣.៣- ថ្ងៃទី២២-២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ចូលរួមសម្របសម្រួលការងារតាំងពិពណ៌អប់រំមីន នៅវិទ្យាល័យថ្មពួក ខេត្តបន្ទាយមានជ័យ  និងចូលរួមស្តាប់ទូទាំងប្រទេស សរុបអ្នកចូលរួម ៩,៧១៤នាក់។





៣.៤- ថ្ងៃទី០៤-០៥ ខែកុម្ភៈ ឆ្នាំ២០១៧ រៀបចំពីធីបរិច្ចាកជើងសិប្បនិម្មិត៣០នាក់ គាំទ្រថវិកា លោក **ភីន សាសៅ** និស្សិតថៃ ដល់ជនពិការនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ អ្នកចូលរួម ៩៥នាក់ទាំងថៃ-ខ្មែរ។





៣.៥- ថ្ងៃទី០៣-០៥ខែមីនា ឆ្នាំ២០១៧ រៀបពិធីប្រគល់ជើងសិប្បនិម្មិតដល់ជនពិការ៣២នាក់ក្នុង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ អ្នកចូលរួម ៩០នាក់ទាំងថៃ-ខ្មែរ។





៣.៦- ថ្ងៃទី១០-០១ ខែមេសា ឆ្នាំ២០១៧ ចូលរួមប្រមែរប្រមូលជើងសិប្បនិម្មិត និងរទេះរុញ ចាស់ៗដើម្បីដាក់តាំងនៅសារមន្ទីរសន្តិភាព របស់ស៊ីម៉ាក់ ខេត្តសៀមរាប។





៣.៧- ថ្ងៃទី២០-២៤ ខែមីនា ឆ្នាំ២០១៧បង្រៀនMREដល់បុគ្គលិកNTS ចំនួន២៨នាក់TIMA នៅខេត្តកំពង់ឆ្នាំង។




៣.៨- គ្រប់ក្រុមស៊ីម៉ាក់ បណ្តាញមីន និងយុទ្ធនាការចុះអប់រំប្រជាពលរដ្ឋជាសាធារណៈ នាថ្ងៃ២៤ កុម្ភៈ ឆ្នាំ២០១៧ ទទួលបានលទ្ធផលខាងក្រោម៖

1. អប់រំបាន ១,៦៥៤លើក
2. តាមខ្នងផ្ទះ១,២៤៦ខ្នង
3. បុរសបាន ១៣,៩៩៤នាក់
4. ស្ត្រីបាន១២,៥៥១នាក់
5. កុមារក្នុងប្រព័ន្ធ៧,៩២៩នាក់
6. កុមារក្រៅប្រព័ន្ធ៣,៦៨១នាក់
7. សរុបទាំងអស់៖**៣៨,១៥៥នាក់**




៣.៩- ថ្ងៃទី០៣ ខែមេសា ដល់២២ ខែឧសភា ឆ្នាំ២០១៧ ចូលរួមប្រមូលគ្រឿងចក្រ រងគ្រោះដោយសារគ្រាប់មីន ដើម្បីដាក់តាំងនៅសារមន្ទីរសន្តិភាព។





៣.១០- ថ្ងៃទី២០-២៤ ខែមេសា ឆ្នាំ២០១៧ បទបង្ហាញបុគ្គលិក UNDP ៣០នាក់ នៅភ្នំពេញ ស្តីពីព័ត៌មានសុវត្ថិភាពគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។




៣.១១- ថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០១៧ ប្រជុំបុគ្គលិកMRE & IMSMA នៅបាត់ដំបង ស្តីពីការពិនិត្យឡើងវិញនូវការអនុវត្តប្រព័ន្ធ MRE & IMSMA និងដកពិសោធន៍ការងារប្រចាំឆ្នាំ កែលំអររកយុទ្ធសាស្រ្តសម្រាប់ឆ្នាំបន្ត។




៣.១២- ថ្ងៃទី១២-៣០ ខែមិថុនា ឆ្នាំ២០១៧ ចូលរួមរៀបចំតាំងពិព៌ណសារមន្ទីរសន្តិភាពនៅ ខេត្តសៀមរាប។




៣.១៣-ថ្ងៃទី១៦-៣០ ខែកក្កដា ឆ្នាំ២០១៧ ចុះសិក្សារកទីតាំងមីនតោន នៅខេត្តប៉ៃលិន និងបាត់ដំបង បាន៦ទីតាំង ដែលមានមីនតោនប្រមាណ៧៧២គ្រាប់ ត្រូវបានគេដាក់បង្កប់ បិតក្នុងខេត្តប៉ៃលិន៤កន្លែង និង២កន្លែងទៀតក្នុងខេត្តបាត់ដំបង។




៣.១៤-ថ្ងៃទី២០-២៣ ខែសីហា ឆ្នាំ២០១៧ ចូលរួមបង្រៀន MRE នៅTIMA CMAC គំរោង JMAS មានសិក្ខាកាមចូលរួមចំនួន១០នាក់។




៣.១៥- ថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ចូលរួមជាមួយនាយកដ្ឋានប្រតិបត្តិការ ក្នុងសកម្មភាពសម្អាតគ្រាប់បែកគីមី នៅភូមិគគីរ ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង។





៣.១៦-ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ចុះប្រមូលព័ត៌មានការទម្លាក់គ្រាប់បែក បេ៥២ នៅភូមិសាស្ត្រ ភូមិមនោរម្យ ឃុំហោងសំណំ ស្រុកឱរាល់ ខេត្តកំពង់ស្ពឺ។





៣.១៧-ថ្ងៃទី០៨-១៤ ខែតុលាឆ្នាំ២០១៧ ចុះសិក្សាតំបន់គោលដៅនិងជ្រើសរើសប៉ូលីស១០០នាក់ និងមេភូមិ១៦០នាក់ លើខេត្តសៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំ សម្រាប់ត្រៀមបើកវគ្គMRE ។





៣.១៨-ថ្ងៃទី១៥-២៨ ខែតុលា ឆ្នាំ២០១៧ ចុះកម្មសិក្សាទៅប្រទេសឡាវ សិក្សានៅ( Laos-Cambodia South-South Cooperation Phase II )ក្នុងខេត្តបីគី ខេត្តចំប៉ាសាក់ សេកុង និងខេត្តសាលាវ៉ន ១សប្តាហ៏ និងមកកម្ពុជា១សប្តាហ៏( ២២ ដល់២៨តុលា ឆ្នាំ២០១៧ ក្នុងខេត្តសៀមរាប និងបាត់ដំបង។





៣.១៩-ថ្ងៃទី២១ ខែវិច្ឆិកា ដល់ថ្ងៃ០២ ធ្នូ ឆ្នាំ២០១៧ ចុះសិក្សា និងជ្រើសរើសបណ្តាញគ្រាប់មិនទាន់ផ្ទុះនិងបើកវគ្គបណ្តុះបណ្តាល ដល់បណ្តាញគ្រាប់ស្ម័គ្រចិត្តចំនួន៦០នាក់ ជាមេភូមិ/មន្ត្រីនគរបាល ក្នុងខេត្តស្វាយរៀង និងព្រៃវែង ព្រមទាំងបើកវគ្គរំលឹកដល់មន្ត្រីនគរបាលគ្រប់គ្រងទិន្នន័យចាស់ចំនួន៧នាក់ ក្នុងខេត្តក្រចេះ កំពង់ចាម និងត្បូងឃ្មុំ។





៣.២០-ថ្ងៃទី១១-១៥ ខែធ្នូ ឆ្នាំ២០១៧ ចូលរួមបង្រៀន MRE ដល់បុគ្គលិកស៊ីម៉ាក់គម្រោង JMAS ចំនួន២០នាក់ នៅTIMA ខេត្តកំពង់ឆ្នាំង។




៣.២១-ថ្ងៃទី១៨-៣០ ខែធ្នូ ឆ្នាំ២០១៧ ចុះបើកវគ្គបណ្តុះបណ្តាល  MRE កសាងសមត្ថភាពដល់មន្ត្រីប៉ូលីស១០០នាក់ ក្នុងខេត្តកំពង់ធំ សៀមរាបឧត្តរមានជ័យ ព្រះវិហារ និងមេភូមិ១៦០នាក់ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។




**៤–លទ្ធផលនៃការសម្របសម្រួលសហការលើសេវាអភិវឌ្ឍន៍ និងសេវាជនពិការ**

ដោយមានគណៈកម្មាធិការមីនស្ម័គ្រចិត្តទាំងបីកម្រិត (ភូមិ ឃុំ និងស្រុក) សុទ្ធតែជាអាជ្ញាធរដែនដី និងមន្ត្រីនៅក្នុងមូលដ្ឋាន ហើយនាយតំណាងមីនប្រចាំស្រុក (DFP) ក៏ជាមន្ត្រីនៅក្នុងមូលដ្ឋាននោះផងដែរ ដូច្នេះ ពួកគេអាចធ្វើការសម្របសម្រួល សហការលើសេវាកម្មទាំងពីរនេះបានយ៉ាងល្អ។ ម្យ៉ាងទៀតដើម្បីឱ្យការអប់រំការយល់ដឹងពីមីនរបស់ពួកគេមានប្រសិទ្ធិភាព គេត្រូវតែខិតខំរកវិធីសាស្ត្រអូសទាញ សេវាអភិវឌ្ឍន៍នានាចូលទៅក្នុងមូលដ្ឋាននោះ ដើម្បីឱ្យមានការផ្លាស់ប្តូរឥរិយាបថ ដល់អ្នកដែលធ្លាប់តែប្រថុយប្រថាន

និងគ្រោះថ្នាក់ខ្ពស់ ហើយលទ្ធផលដែលទទួលបានមកពីការសម្របសម្រួល លើសេវាកម្មនេះមានដូចខាងក្រោម៖

៤.១-សេវាអភិវឌ្ឍន៍

| លរ | សមិទ្ធិផល | ប្រភេទ | សរុបលទ្ធផលនិងអ្នកទទួលផល | | | | អ្នកគាំទ្រថវិកា |
|---|---|---|---|---|---|---|---|
| | | | លទ្ធផល | មនុស្សរាយ | គ្រួសារ | ភូមិ | |
| 1 | ផ្លូវក្រាលគ្រួសក្រហម | Meter | 23,450 | 8,6547 | 52,901 | 65 | មន្ទីរអភិវឌ្ឍន៍, មូលនិធិឃុំ, សហគមន៍,មន្ទីរសាធារណការ |
| 2 | ជួសជុលផ្លូវ | Meter | 214,920 | 240,280 | 271,601 | 110 | សប្បុរសជន,មន្ទីរសាធារណៈការ |
| 3 | ផ្លូវលំថ្មី | Meter | 30,169 | 2,096 | 1,725 | 54 | មូលនិធិឃុំ,សប្បុរសជន, |
| 4 | លូមូល | Place | 34 | 0 | 1,902 | 23 | មូលនិធិឃុំគុំ,សប្បុរសជន |
| 5 | ប្រឡាយទឹក | Meter | 2,340 | 563 | 103 | 10 | មន្ទីរអភិវឌ្ឍន៍, |
| 6 | ស្រះទឹក | Plot | 123 | 0 | 2,767 | 32 | មន្ទីរអភិវឌ្ឍន៍, |
| 7 | សាលារៀន | Ea | 25 | 56,739 | 6,321 | 65 | កុមារក្តីសង្ឃឹម,Japan,រាជរដ្ឋាភិបាល |
| 8 | អណ្តូងស្នប់ | Ea | 341 | 0 | 1,987 | 45 | មន្ទីរអភិវឌ្ឍន៍ |
| 9 | ជួសជុលអណ្តូងស្នប់ | Ea | 549 | 0 | 2,321 | 38 | មន្ទីរអភិវឌ្ឍន៍, |
| 10 | ពាងទឹក | Ea | 455 | 2,957 | 397 | 41 | មន្ទីរអភិវឌ្ឍន៍,កាកបាទក្រហម, |
| 11 | ធុងចម្រោះទឹក | Ea | 1,204 | 1,245 | 432 | 53 | CWS,CDO,កាកបាទក្រហម |
| 12 | អង្ករសំរាប់ជួយបន្ទាន់ | kg | 6,690 | 1,968 | 454 | 47 | W.V.C,កាកបាទក្រហម |
| 13 | បង្គន់ | Ea | 1,253 | 3,945 | 934 | 45 | មន្ទីរអភិវឌ្ឍន៍,កាកបាទក្រហម |

៤.២-សេវាកម្មជនពិការ

| លរ | សមិទ្ធផល | ប្រភេទ | សរុបលទ្ធផលនិងអ្នកទទួលផល | | | | អ្នកគាំទ្រថវិកា |
|---|---|---|---|---|---|---|---|
| | | | ចំនួនលទ្ធផល | មនុស្សរាយ | គ្រួសារ | ភូមិ | |
| 1 | ជើងសិប្បនិម្មិតថ្មី | Ea | 3,890 | 3,890 | 0 | 145 | ICRC,Tromacare,Thailand |
| 2 | ជួសជុលជើងសិប្បនិម្មិត | Ea | 2,138 | 2,138 | 0 | 87 | ICRC, |
| 3 | រទេះរុញថ្មី | Ea | 34 | 34 | 0 | 25 | ICRC, Thailand |
| 4 | ឈើច្រត់ថ្មី | Ea | 56 | 56 | 0 | 21 | ICRC, |

ឃ-សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០១៧កន្លងទៅនេះ ស្ថានភាពរងគ្រោះថ្នាក់ដោយសារមីន/គ្រាប់មិនទាន់ផ្ទុះ បានថយចុះប្រមាណ៣០%នៃអត្រាគ្រោះថ្នាក់ឆ្នាំ២០១៦កន្លងទៅ ដែលជាអត្រាគ្រោះថ្នាក់ថយចុះមួយគួរឱ្យកត់សម្គាល់ ជាមួយគ្នានេះយើងសង្កេតឃើញថា ការគ្រោះថ្នាក់កន្លងមកភាគច្រើន មានដូចជាការដុតផាវបោកត្រី ការលេងគ្រាប់ ការប្រកបមុខរបរក្នុងតំបន់សង្ស័យមានមីន។ល។ ទាំងនេះជាទង្វើប្រថុយប្រថានណាស់ ហើយករណីទាំងអស់នេះវាគឺជាពិសោធន៍មួយយ៉ាងសំខាន់ក្នុងការបង្កើន និងជំរុញការងារអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/គ្រាប់មិនទាន់ផ្ទុះឱ្យបានផុលផុសគ្រប់ទីកន្លែង ពិសេសនៅក្នុងជួរថ្នាក់ដឹកនាំជាមេភូមិ-

នាយប៉ុស្តិ៍នគរបាលឃុំ/សង្កាត់។ ពីព្រោះពួកគាត់គឺជាអ្នកអនុវត្តន៍ផ្ទាល់នូវគោលនយោបាយ “ ភូមិ-ឃុំមានសុវត្ថិភាព” ជាប់ផ្ទាល់ជាមួយសហគមន៍មូលដ្ឋានតែម្តង។ បច្ចុប្បន្ននេះក្រសួងមហាផ្ទៃបានបង្កើន និងជំរុញសកម្មភាពអប់រំផ្សព្វផ្សាយយ៉ាងខ្លាំងក្លា ដោយកំណត់ក្នុងមួយខែ ប៉ុស្តិ៍និមួយៗត្រូវចុះអប់រំឱ្យបានបួនដងយ៉ាងតិច បើប៉ុស្តិ៍ណាអនុវត្តបានល្អជាងគេនឹងមានជូនរង្វាន់លើកទឹកចិត្តទៀតផង។

ដូច្នេះវាជាឱកាសល្អសម្រាប់ការងារអប់រំមីនរបស់យើង ដែលគួរតែពង្រីកបណ្តាញមន្ត្រីនគរបាលផ្នែកគ្រប់គ្រងកិច្ចការប៉ុស្តិ៍ចាប់ពីថ្នាក់ឃុំ/សង្កាត់ ស្រុក និងខេត្ត ឱ្យបានទូទាំង២៥ខេត្ត/ក្រុង ដោយគ្រាន់តែយើងផ្តល់ជំនាញ អប់រំផ្សព្វផ្សាយយល់ដឹងពីមីន និងជំនាញអភិវឌ្ឍន៍សហគមន៍ដល់ពួកគាត់ និងផ្តល់ថវិកាលើកទឹកចិត្តជា Cell card ឬសេវាកម្មរដ្ឋបាលមួយចំនួន យើងនឹងទទួលបានលទ្ធផលយ៉ាងវិសេសវិសាលបំផុត។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័កព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨

អ្នករៀបត្រួតពិនិត្យ
អនុប្រធាននាយកដ្ឋាន
MRE/VA/PCD

**ញ៉ៀប សៃ**

អ្នករៀបចំរបាយការណ៍
ប្រធានការិយាល័យ
MRE/VA/PCD

**ឃីម ថន**